Clean Water Plan

Making the right investments at the right time

King County
Department of Natural Resources and Parks
Wastewater Treatment Division

ហេតុអ្វីបានជាកន្លែងរំដោះទឹក (CSO) កើតឡើង?

ដំណោះស្រាយពីអតីតកាលបង្កើតជាបញ្ហានៅពេលបច្ចុប្បន្ន។

នៅក្នុងផ្នែកចាស់ៗនៃប្រព័ន្ធបង្ហូរទឹកស្អុយរបស់ខោនធី King កន្លែងរំដោះទឹកដែលហៅថា “កន្លែងរំដោះទឹកស្អុយហៀរចេញពីលូរួម” ឬ CSO ត្រូវបានបំពាក់ទៅក្នុងបំពង់លូ។ CSO បញ្ចេញទឹកកខ្វក់ក្នុងផ្លូវទឹកក្នុងតំបន់នៅពេលទឹកភ្លៀងធ្លាក់ពេញបំពង់លូ។ ការរំដោះទឹកនេះ ទប់ស្កាត់ការហូរហៀរទឹកលូចូលទៅក្នុងលំនៅដ្ឋាន និងតាមដងផ្លូវ។ វាសមហេតុផលកាលពីពេលនោះ...



ចាប់ពីចុងទសវត្សឆ្នាំ 1800 រហូតដល់ទសវត្សឆ្នាំ 1940 វិស្វករបានរចនាប្លង់លូទឹកដើម្បីនាំ ទឹកស្អុយនិងទឹកភ្លៀងទៅកាន់ប្រភពទឹកដែលជិតបំផុត។ នៅពេលនោះ អ្នករៀបចំផែនការ បានជឿជាក់ថាសារធាតុពុលដែលត្រូវបានពង្រាវនឹងមិនមានផលអាក្រក់ដល់ប្រភពទឹកទេ។ ប្រព័ន្ធនោះប្រមូលយកលាមកសេះ និងសំរាមតាមដងផ្លូវរួមជាមួយនឹងកាកសំណល់របស់ មនុស្សផងដែរ។



ក្រោយមក វិស្វករបានសាងសង់រោងចក្រប្រព្រឹត្តកម្ម ដើម្បីសម្អាតទឹកនោះមុនពេលបញ្ជូនវាទៅ ក្នុងបរិស្ថាន។ ហើយពួកគេបានសាងសង់បំពង់ធំៗដែលគេហៅថា “លូរួម” ដើម្បីនាំទឹកទាំងនេះ ទៅកាន់រោងចក្រប្រព្រឹត្តកម្មទឹកស្អុយ។

នៅពេលភ្លៀងធ្លាក់ខ្លាំងពេញ “លូរួម” កន្លែងរំដោះទឹក (បំពង់បង្ហូរទឹកចេញ) បញ្ជូនទឹកស្អុយ និងទឹកភ្លៀងដែលលើស ទៅក្នុងទន្លេ បឹង ឬព្យែដែតសោន។



សព្វថ្ងៃនេះ ទីក្រុងនានានៅក្នុងខោនធី King សាងសង់បំពង់លូដាច់ដោយឡែកពីគ្នា បំពង់លូមួយសម្រាប់នាំទឹកស្អុយទៅក្នុងរោងចក្រប្រព្រឹត្តកម្ម និងបំពង់លូមួយទៀត សម្រាប់នាំទឹកភ្លៀងទៅកាន់ប្រភពទឹកដែលនៅជិតបំផុត។ ទោះជាយ៉ាងណាក្តី នៅតែមានលូរួម នៅតាមតំបន់ចាស់ជាងគេមួយចំនួននៅ Seattle ។

Khmer

KCIT-DCE file: 2008_10227L_CWP_CSOinfosSht_KHMER.docx